**អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍**

# របាយការណ៍
# ស្តីពី
# ការសិក្សាអង្កេតជ្រើសរើសតំបន់គោលដៅអនុវត្តគំរោង
# នៅក្នុងស្រុកត្បូងឃ្មុំស្រួច ខេត្តកំពង់ស្ពឺ
# ២៣-២៤ តុលា ២០០៧

## I. សេចក្តីផ្តើម

អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ គឺជាអង្គការមិនមែនរដ្ឋាភិបាលមិនរកប្រាក់ចំណេញផ្នែកខាងការងារអភិវឌ្ឍន៍ និងស្រាវជ្រាវ ដែលផ្តោតសំខាន់លើការពង្រឹងសមត្ថភាពនិស្សិត, ការអភិវឌ្ឍន៍ប្រព័ន្ធអេកូឡូស៊ី កសិកម្ម និងការអភិវឌ្ឍន៍ជនបទចំរុះដែលមានលក្ខណៈនិរន្តរភាពផ្នែកធនធានធម្មជាតិ និងបរិស្ថាន។ អង្គការ ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ២០០៥ ដោយសមាជិកស្ថាបនិកកម្ពុជាដែលមានចំណេះដឹង និងបទពិសោធន៍ចំនួន៦រូប ព្រមទាំងមានការគាំទ្រពីសមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់ចំនួន ៥រូប។ យើងមានឆន្ទៈ និងការតាំងចិត្តខ្ពស់ក្នុងការបំពេញការងារផ្នែកអភិរក្ស និងអភិវឌ្ឍន៍ ក្នុងគោលបំណងដើម្បីរួមចំណែកធ្វើអោយប្រសើរឡើងនូវលក្ខណៈរស់នៅរបស់ប្រជាកសិករក្រីក្រនៅក្នុងសហគមន៍។ អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ ប្រកាន់ខ្ជាប់នូវបាវចនា ***សមត្ថភាព គុណភាព និងតម្លាភាព*** ដែលវាបានឆ្លុះបញ្ចាំងអោយឃើញពីការប្តេជ្ញាចិត្ត និងទទួលខុសត្រូវខ្ពស់នៅក្នុងការបំពេញបេសកកម្មរបស់ខ្លួនជាមួយនឹងផ្លែផ្កាដ៏ត្រចះត្រចង់ ដើម្បីផ្តល់ជាប្រយោជន៍ដល់ក្រុមគោលដៅ និងបង្កើតជាគំរូមួយសំរាប់អនុវត្តតាម។

អស់រយៈពេលជិតពីរឆ្នាំចាប់តាំងពីឆ្នាំ២០០៦ រហូតមកដល់បច្ចុប្បន្ន អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ បានបំពេញបេសកកម្មរបស់ខ្លួនយ៉ាងសកម្ម ស្របតាមទស្សនៈវិស័យរបស់អង្គការដែលបានចែងថា ***"សង្គមកម្ពុជាមួយដែលប្រជាពលរដ្ឋមានសមត្ថភាព ប្រកបដោយគុណភាព និងប្រសិទ្ធិភាព ចេះជួយគ្នាទៅវិញទៅមក ព្រមទាំងរស់នៅក្នុងជីវភាពមួយដែលមានលក្ខណៈថ្លៃថ្នូរ និងពោរពេញទៅដោយបរិស្ថានល្អ "*** ។ លទ្ធផលនៃការអនុវត្តសកម្មភាព របស់អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ រួមមាន :

- ការបង្កើតវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់និស្សិត និងបុគ្គលិកអង្គការ-ស្ថាប័នពាក់ពន្ធ
- ការបណ្តុះបណ្តាលដល់ប្រជាកសិករនៅភូមិកន្លែងរមាស ឃុំពេជ្រមុន្នី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ស្តីពីបច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារតាមគោលការណ៍ធម្មជាតិ-ការរៀបចំសួនបន្លែគ្រួសារ, ព្រមទាំងការ

ធ្វើបង្ហាញជាក់ស្តែងពីការចិញ្ចឹមមាន់ និងសួនបន្លែគ្រួសារ ។

- ការរៀបចំក្រុមសន្សំជួយខ្លួនឯង នៅភូមិកន្លែងរមាស ឃុំពេជ្រមុន្នី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ
- ការសិក្សាអង្កេត និងស្រាវជ្រាវ ទាក់ទងនឹងប្រធានបទជាច្រើន ដូចជាកំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទមួយចំនួន, ស្ថានភាពសុខភាព, ស្ថានភាពការប្រើប្រាស់ថ្នាំកសិកម្ម ។ល ។
- ការចេញផ្សាយព្រឹត្តិបត្តិប្រចាំខែឈ្មោះថា *" ពតិមានសំខាន់សំរាប់អ្នក "* ដើម្បីផ្សព្វផ្សាយអោយបានទូលំទូលាយដល់ស្រទាប់ប្រជាកសិករ និងនិស្សិត សំដៅបង្កើនសមត្ថភាព និងផលិតភាពផ្នែកកសិកម្ម ។
- ការបើកជាបណ្ណាល័យសំរាប់សាធារណជនទូទៅចូលអាន សិក្សាស្រាវជ្រាវ បង្កើនសមត្ថភាពបន្ថែម

ផ្អែកតាមលទ្ធផលនៃការជជែកពិភាក្សាពីលទ្ធភាពនៃការធ្វើជាដៃគូជាមួយគ្នា រវាងអង្គការសហប្រតិបត្តិការកាតូលិក អូស្ត្រាលី-កម្ពុជា (ACR) និងអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ (ARD) ដែលក្នុងនោះមាន :

- ការជជែកពិភាក្សារបស់តំណាងអង្គការ ACR ដើម្បីស្វែងយល់ពីប្រវត្តិ រចនាសម្ព័ន្ធ និងការអនុវត្តសកម្មភាពរបស់អង្គការ ARD នៅការិយាល័យអង្គការ ARD ថ្ងៃទី១៧ កញ្ញា ២០០៧ ដោយមានការចូលរួមពីលោក សួន សុខេង នាយកអង្គការ ARD, លោក ឡាយ សុធី អ្នកសំរបសំរួលកម្មវិធីភាពជាដៃគូ របស់អង្គការ ACR និងអ្នកស្រី សុខុន ស៊ីណូដា មន្ត្រីកម្មវិធីរបស់អង្គការ ACR
- ការចុះសិក្សាស្វែងយល់របស់តំណាងអង្គការ ACR ស្តីពីការអនុវត្តគំរោងសកម្មភាពជាក់ស្តែងនៅភូមិកន្លែងរមាស ឃុំពេជ្រមុន្នី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ នាថ្ងៃទី ១៨ កញ្ញា ២០០៧ ដោយមានការចូលរួមពីលោក ឡាយ សុធី អ្នកសំរបសំរួលកម្មវិធីភាពជាដៃគូរបស់អង្គការ ACR, អ្នកស្រី សុខុន ស៊ីណូដា មន្ត្រីកម្មវិធីរបស់អង្គការ ACR, អ្នកស្រី ចាប សុវណ្ណរស្មី ជំនួយការគ្រប់គ្រងអង្គការ ARD , និងលោក នេត សុភិរុន អ្នកសំរបសំរបអភិវឌ្ឍន៍សហគមន៍អង្គការ ARD
- ការចុះសិក្សាអង្កេតដើម្បីជ្រើសរើសតំបន់គោលដៅអនុវត្តគំរោងថ្មីនៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ នៅថ្ងៃទី ០៤ តុលា ២០០៧ ដោយមានការចូលរួមពីលោក ឡាយ សុធី អ្នកសំរបសំរួលកម្មវិធីភាពជាដៃគូរបស់អង្គការ ACR, អ្នកស្រី សុខុន ស៊ីណូដា មន្ត្រីកម្មវិធីរបស់អង្គការ ACR និងលោក សួន សុខេង នាយកអង្គការ ARD ។

ក្រុមការងាររបស់អង្គការ ARD បានរៀបចំការសិក្សាអង្កេតដើម្បីជ្រើសរើសតំបន់គោលដៅសំរាប់អនុវត្តន៏គំរោងនៅក្នុងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដែលមានរយៈពេល២ថ្ងៃ ។

## II. គោលបំណង

ការសិក្សាអង្កេតដែលមានរយៈពេល២ថ្ងៃ ត្រូវបានរៀបចំឡើងដោយក្រុមការងាររបស់អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ ក្នុងគោលបំណងសំខាន់ចំនួន២ ដូចខាងក្រោម :

- សិក្សាស្វែងយល់ពីស្ថានភាពទូទៅនៅក្នុងភូមិសាស្ត្ររបស់ឃុំមួយចំនួននៅក្នុងស្រុកភ្នំស្រួច
- លើកជាអនុសាសន៍ក្នុងការជ្រើសរើសភូមិ-ឃុំមួយចំនួនសំរាប់ជាទីតាំងគោលដៅអនុវត្តគំរោង

## III. អ្នកចូលរួម និងកាលបរិច្ឆេទ

ការសិក្សាអង្កេតដើម្បីជ្រើសរើសតំបន់គោលដៅអនុវត្តគំរោងនេះ ធ្វើឡើងរយៈពេល២ថ្ងៃ គឺនៅថ្ងៃទី ២៣-២៤ ខែតុលា ឆ្នាំ២០០៧ ដែលចូលរួមដោយ :

១. លោក សួន សុខេង នាយកប្រតិបត្តិអង្គការ ARD

២. លោក មុំ សុខា អ្នកសំរបសំរួលអភិវឌ្ឍន៍សហគមន៍ អង្គការ ARD

## IV. វិធីសាស្រ្តសិក្សាអង្កេត

វិធីសាស្រ្តសំខាន់ៗចំនួនពីរដែលបានប្រកាន់យកសំរាប់ធ្វើការសិក្សាអង្កេតនេះ គឺការអង្កេតជាក់ស្តែងនៅក្នុងភូមិនីមួយៗ និងការជួបពិភាក្សាដោយផ្ទាល់ជាមួយអ្នកពាក់ព័ន្ធ ដែលក្នុងនោះមាន :

- ការពិភាក្សាជាមួយតំណាងអង្គការ **LWF** ប្រចាំស្រុកភ្នំស្រួច
- ការជួបពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ និងអជ្ញាធរភូមិ
- ការជួបពិភាក្សាជាមួយប្រជាកសិករនៅក្នុងភូមិ

## V. ឃុំដែលបានធ្វើការសិក្សាអង្កេត

យោងទៅតាមការជជែកពិភាក្សាជាមួយលោក ឃិន ម៉ាប់ បុគ្គលិកអង្គការ **LWF** ប្រចាំស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ យើងបានសំរេចធ្វើការសិក្សាអង្កេតទៅលើឃុំចំនួន ៦ គឺ**ឃុំជាំសង្កែ, ព្រៃក្មេង, មហាសាំង, អូរ, គីរីវ័ណ្ណ និងឃុំត្រែងត្រយឹង** ។ មូលហេតុដែលជ្រើសរើសយកឃុំទាំង៦នេះ ដើម្បីធ្វើការសិក្សាអង្កេត ពីព្រោះឃុំទាំងនេះ មិនមែនជាឃុំគោលដៅរបស់អង្គការ **LWF** លើកលែងតែឃុំត្រែងត្រយឹងមួយចេញដែលអង្គការ **LWF** បានធ្វើការ ប៉ុន្តែមិនបានគ្របដណ្តប់គ្រប់ភូមិនោះឡើយ ។ គំរោងសកម្មភាពរបស់អង្គការ **LWF** គឺការអភិវឌ្ឍន៍ចំរុះដើម្បីលើកស្ទួយការិតជីវភាពរស់នៅរបស់ប្រជាកសិករក្រីក្រ ដោយរួមទាំងខាងផ្នែកកសិកម្មផងដែរ ដែលស្រដៀងគ្នានឹងអង្គការ **ARD** ហេតុនេះយើងមិនអាចជ្រើសរើសភូមិគោលដៅត្រួតគ្នាឡើយ ។

## VI. លទ្ធផលនៃការសិក្សាអង្កេត

### ១. ឃុំជាំសង្កែ :

ឃុំជាំសង្កែ គឺជាឃុំមួយដែលមានទីតាំងស្ថិតនៅឆ្ងាយដាច់ស្រយាលពីផ្លូវជាតិលេខ៤ ជាប់នឹងស្រុកបរសេដ្ឋ ហើយមានស្ថានភាពក្រីក្រជាងឃុំទាំង៥ផ្សេងទៀតដែលក្រុមការងារអង្គការ **ARD** បានចុះធ្វើការសិក្សាអង្កេត។ តាមការជួបពិភាក្សាជាមួយលោកខ្សៅ ជា មេឃុំ និងលោក សែម សារ៉េត ស្មៀនឃុំជាំសង្កែបានអោយដឹងថា ឃុំនេះមានភូមិចំនួន៧ដែលស្ថិតនៅក្រោមចំណុះរដ្ឋបាលគ្រប់គ្រងរបស់ឃុំជាមួយនឹងចំនួនប្រជាពលរដ្ឋរស់នៅបច្ចុប្បន្ន ដូចសង្ខេបនៅក្នុងតារាងខាងក្រោមនេះ

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ | ផ្ទៃដីស្រែ (ហិកតា) | ផ្ទៃដីចំការ (ហិកតា) |
|---|---|---|---|---|
| ១ | ក្បាលទឹកលើ | ១០៩ | ២៨២ | ១២០ |
| ២ | ដូង | ១៦៤ | ២២០ | ១៣០ |
| ៣ | តានៃ | ៦៥ | ៨៣ | ៨០ |
| ៤ | ព្រៃឬស្សី | ២៦២ | ២១១ | ១៣០ |
| ៥ | ក្បាលទឹកក្រោម | ១៣០ | ១៦០ | ៨០ |
| ៦ | ថ្មី | ២០២ | ២០០ | ១១០ |
| ៧ | សាលា | ១០១ | ១៤៥ | ១០០ |
| **សរុប** | | **១០៣៣** | **១៣០១** | **៧៥០** |

**ស្ថានភាពរួមរបស់ប្រជាពលរដ្ឋ** : តាមរយៈការសង្កេតជាក់ស្តែង និងការជួបពិភាក្សាជាមួយប្រជាពលរដ្ឋនៅតាមភូមិមួយចំនួន យើងវាយតំលៃបានថាប្រជាពលរដ្ឋក្នុងឃុំជាំសង្កែទាំងមូលរស់នៅអាស្រ័យជាចំបងទៅលើមុខរបរធ្វើស្រែដើម្បីចិញ្ចឹមជីវិត នៅក្នុងខណៈដែលគ្រួសារខ្លះមានមុខរបរបន្ទាប់បន្សំដូចជាធ្វើចំការជាលក្ខណៈគ្រួសារ (ដាំអំពៅ, បន្លែបង្ការូមផ្សំ)។ *ទោះបីជាកសិករមានមុខរបរធ្វើស្រែជាចំបង ប៉ុន្តែចំណេះដឹង និងការអនុវត្តជាក់ស្តែងទាក់ទងបច្ចេកទេសធ្វើស្រែរបស់ពួកគាត់នៅមានកំរិតទាប ដែលទិន្នផលទទួលបានជាមធ្យមត្រឹមតែ ១,៥តោនប៉ុណ្ណោះក្នុង១ហិកតា។* ក្នុងរយៈពេល៣ឆ្នាំ ចាប់ពីឆ្នាំ២០០៤ រហូតដល់ឆ្នាំ២០០៦ ឃុំជាំសង្កែទាំងមូលជួបប្រទះនឹងគ្រោះរាំងស្ងួត ដែលធ្វើអោយស្រូវរបស់ប្រជាកសិករទាំងអស់ត្រូវខូចខាតទាំងស្រុង ហើយត្រូវជួបប្រទះនឹងការខ្វះខាតស្បៀងយ៉ាងធ្ងន់ធ្ងរ។ ទោះបីជាយ៉ាងណាក៏ដោយ ស្ទើរគ្រប់គ្រួសារទាំងអស់នៅគ្រប់ភូមិ ប្រជាកសិករមានចិញ្ចឹមគោដែលជាកំលាំងអូសទាញដ៏សំខាន់នៅក្នុងការធ្វើស្រែចំការរបស់ខ្លួន ប៉ុន្តែនៅក្នុងឃុំនេះទាំងមូលហាក់ដូចជាក្លាយទៅទំលាប់មួយទៅហើយដែលប្រជាពលរដ្ឋភាគច្រើនមិនដែលលក់គោរបស់ខ្លួនឡើយ ហេតុនេះហើយចំនួនគោចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ តាមការអោយដឹងពីមេឃុំជាំសង្កែបានអោយដឹងថា នៅពេលមានឈ្មួញមករកទិញគោនៅក្នុងភូមិ ប្រជាជនតែងតែកាត់ក្នុងតំលៃខ្ពស់ (ហាក់ជាធ្វើមិនចង់លក់) ដែលធ្វើអោយឈ្មួញមិនហ៊ានទិញ។

**បញ្ហាចំបងដែលជួបប្រទះនៅក្នុងឃុំ :**

- ខ្វះចំណេះដឹងបច្ចេកទេសផ្នែកធ្វើកសិកម្ម
- ខ្វះស្បៀង (តែងតែជួបប្រទះញឹកញាប់នូវគ្រោះរាំងស្ងួត)
- ខ្វះប្រភពទឹក
- បញ្ហាសុខភាព (ប្រជាពលរដ្ឋភាគច្រើនកើតជំងឺក្រពះ-ពោះវៀន, គ្រុនចាញ់) និងអនាម័យ
- អំពើហឹង្សាក្នុងគ្រួសារ

**វត្តមានរបស់អង្គការនានា :** ថ្វីត្បិតតែឃុំជាំសង្កែ ជាឃុំមួយដាច់ស្រយាលពីផ្លូវជាតិ ហើយប្រជាពលរដ្ឋរស់នៅប្រកបរបរដោយពឹងផ្អែករបរកសិកម្មជាចំបង ប៉ុន្តែនៅក្នុងឃុំនេះមិនមានវត្តមានអង្គការធ្វើសកម្មភាពគួរអោយកត់សំគាល់ឡើយ លើកលែងតែអង្គការមួយចំនួនដូចខាងក្រោម :

- អង្គការម្លប់បៃតង : អនុវត្តគំរោងសហគមន៍ព្រៃឈើ
- អង្គការ Prasac និងធនាគារ ACELEDA : អនុវត្តគំរោងឥណទានកម្ចីប្រាក់
- អង្គការ CEDAC : ទើបតែធ្វើការទំនាក់ទំនងដើម្បីអនុវត្តគំរោងក្នុងការជំរុញអោយកសិករធ្វើស្រូវម្រិះតាមគោលការណ៍ធម្មជាតិ ។

**អនុសាសន៍របស់ក្រុមការងារអង្គការ ARD** : យោងតាមលទ្ធផលនៃការអង្កេតជាក់ស្តែង និងជួបពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ ប្រជាពលរដ្ឋ យើងឃើញថា *ឃុំជាំសង្កែ ជាឃុំមួយមានលក្ខណៈសមស្របសំរាប់ធ្វើការជ្រើសរើសជាឃុំគោលដៅដើម្បីអនុវត្តគំរោងអភិវឌ្ឍន៍ចំរុះ* (ជាពិសេសផ្តោតលើការបណ្តុះបណ្តាលប្រជាកសិករអោយមានការយល់ដឹងទាក់ទងនឹងបច្ចេកទេសដាំដុះ និងចិញ្ចឹមសត្វ, ការធ្វើបង្ហាញពីបច្ចេកទេសផលិតកម្មកសិកម្ម, ការអប់រំផ្សព្វផ្សាយពីការថែរក្សាធនធានធម្មជាតិ-បរិស្ថាន និងសុខភាព-អនាម័យ, គំរោងបង្កើនសន្តិសុខសុវត្ថិភាពស្បៀងតាមរយៈការបង្កើតធនាគារស្រូវ បង្កើតក្រុមសន្សំ ជាដើម, ការអប់រំផ្សព្វផ្សាយអំពីគោលគំនិតអភិវឌ្ឍន៍-ការផ្លាស់ប្តូរទំលាប់មិនសមស្រប-អំពើហឹង្សាក្នុងគ្រួសារ ។ល ។) សំដៅឈានទៅរកការកែលំអកំរិតជីវភាពរបស់ប្រជាកសិករ តាមរយៈការអនុវត្តនូវបច្ចេកទេសកសិកម្មសមស្រប និងជោគជ័យ និងការធ្វើអោយស្ថានភាពសុខភាពមានភាពល្អប្រសើរឡើង ។ ពិតមែនតែប្រជាពលរដ្ឋនៅឃុំជាំសង្កែហាក់មានធនធានសមស្របសំរាប់ជួយអោយជីវភាពរបស់គាត់មានភាពប្រសើរឡើង ប៉ុន្តែតាមការសិក្សាអង្កេតបង្ហាញថាប្រជាពលរដ្ឋមានចំណេះដឹងទាប ការធ្វើស្រែគឺអនុវត្តតាមតែទំលាប់ មិនមានការយកចិត្តទុកដាក់ថែទាំ និងជាពិសេសគឺខ្វះទាំងស្រុងនូវគំនិតឆ្នៃប្រឌិត ដែលទាមទារអោយមានអ្នកគាំទ្រសំរាប់ជួយតំរង់ទិស ។ ម្យ៉ាងទៀតតាមរយៈការជួបពិភាក្សាជាមួយមេឃុំជាំសង្កែ គាត់បានបង្ហាញនូវភាពអំណត់ព្យាយាម និងទំនាក់ទំនងល្អជាមួយក្រុមការងារ ទោះបីជាការពិភាក្សាត្រូវបានពន្យាររហូតដល់ម៉ោង ១៣:៣០ នាទី រំខានដល់ពេលវេលាសំរាប់បាយថ្ងៃត្រង់ក៏ដោយ ។ លើសពីនេះទៅទៀតមេឃុំជាំសង្កែចាប់អារម្មណ៍យ៉ាងខ្លាំង និងសំណូមពរដល់ក្រុមការងារអង្គការ ARD អោយជួយជាពិសេសលើការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មសមស្របសំរាប់កសិករនៅក្នុងឃុំរបស់គាត់ ។

*ភូមិសាលា និងភូមិតានៃ គឺជាភូមិដែលមានស្ថានភាពក្រីក្រជាងគេក្នុងឃុំ ដែលគួរតែត្រូវបានបញ្ចូលជាភូមិគោលដៅគំរូសំរាប់អនុវត្តសកម្មភាពគំរោងចំរុះ នៅពេលដែលភូមិនានាដទៃទៀតគួរត្រូវបានផ្តោតជាសំខាន់សំរាប់សកម្មភាពផ្សព្វផ្សាយ និងបណ្តុះបណ្តាល ។*

## ២. ឃុំព្រៃក្មេង :

ឃុំព្រៃក្មេង មានទីតាំងស្ថិតនៅជាប់ជាមួយឃុំជាំសង្កែ, ឃុំអូរ, មហាសាំង និងឃុំគីរីវណ្ណ ព្រមទាំងមួយផ្នែកជាប់នឹងស្រុកបរសេដ្ឋផងដែរ ។ លោក ឃឹម ស៊ុន មេឃុំព្រៃក្មេង ព្រមទាំងសមាជិកក្រុមប្រឹក្សាឃុំចំនួនពីររូបផ្សេងទៀតបានអោយដឹងថា ឃុំព្រៃក្មេង គឺជាឃុំមួយដែលទើបធ្វើសមាហរណកម្មចូលជាមួយរដ្ឋាភិបាលក្រោយគេបំផុតរបស់ខ្មែរក្រហម ទោះបីជាទីតាំងរឹងមាំរបស់ខ្លួននៅប៉ៃលិនត្រូវបានចុះចូលមុនរួចហើយក៏ដោយ ដែលជាហេតុធ្វើអោយការអភិវឌ្ឍន៍នៅក្នុងឃុំនេះ ហាក់មានភាពយឺតយ៉ាវជាងបណ្តាឃុំនានា ។ ឃុំព្រៃក្មេង មានភូមិចំនួន៨ ដែលស្ថិតនៅក្រោមចំណុះការគ្រប់គ្រងផ្នែករដ្ឋបាល ហើយដែលត្រូវបានបង្ហាញក្នុងតារាងសង្ខេបដូចខាងក្រោម :

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ |
|---|---|---|
| ១ | ព្រៃ | ៥៥ |
| ២ | ក្រៀលបួស | ៥៦ |
| ៣ | ស្រែត្រពាំង | ៧៧ |
| ៤ | ដីក្រហម | ៨២ |
| ៥ | ព្រៃឈើទាល | ១០៤ |
| ៦ | ព្រៃក្បុង | ១៥៧ |
| ៧ | ដៃថ្មី | ១០២ |
| ៨ | កណ្តាល | ៨៧ |
| **សរុប** | | **៧២០** |

**ស្ថានភាពរួមរបស់ប្រជាពលរដ្ឋ :** មិនខុសពីនៅឃុំជាំសង្កែ ប្រជាពលរដ្ឋក្នុងឃុំព្រៃក្មេងទាំងមូលរស់នៅអាស្រ័យជាចំបងទៅលើមុខរបរធ្វើស្រែដើម្បីចិញ្ចឹមជីវិត នៅក្នុងខណៈដែលគ្រួសារខ្លះមានមុខរបរបន្ទាប់បន្សំដូចជាធ្វើចំការជាលក្ខណៈគ្រួសារ (ដាំអំពៅ, ឪឡឹក, ដំឡូងជ្វា) និងកូនចៅធ្វើការងារនៅរោងចក្រ។ *ទោះបីជាកសិករមានមុខរបរធ្វើស្រែជាចំបង ប៉ុន្តែចំណេះដឹង និងការអនុវត្តជាក់ស្តែងទាក់ទងបច្ចេកទេសកសិកម្មរបស់ពួកគាត់មានកំរិតទាប ដែលទិន្នផលទទួលបានជាមធ្យមត្រឹមតែ១,៥តោនប៉ុណ្ណោះក្នុង១ហិកតា។* គោ ជាសត្វពាហនៈពេញនិយមសំរាប់ប្រជាកសិករស្ទើរគ្រប់គ្រួសារទាំងអស់នៅគ្រប់ភូមិ នៃឃុំព្រៃក្មេងនេះចិញ្ចឹមជាកំលាំងអូសទាញដ៏សំខាន់នៅក្នុងការធ្វើស្រែចំការរបស់ខ្លួន ប៉ុន្តែមានលក្ខណៈស្រដៀងគ្នានឹងនៅឃុំជាំសង្កែដែរ ប្រជាកសិករនៅឃុំព្រៃក្មេងហាក់មានទំលាប់មិនចង់លក់គោរបស់ខ្លួន សំរាប់យកប្រាក់ចំណូលឡើយ។ ឃុំព្រៃក្មេងនេះ ប្រជាកសិករភាគច្រើនទំនេរ ដែលពួកគាត់តែងតែយកឱកាសនេះនៅក្នុងការជួបជុំគ្នាលេងល្បែងស៊ីសង ហូបគ្រឿងស្រវឹង ដែលជាកត្តាសំខាន់មួយទៀតជំរុញអោយកើតមានបញ្ហាទំនាស់ក្នុងគ្រួសារ អំពើហឹង្សាក្នុងគ្រួសារ និងភាពក្រីក្រកាន់តែញាំញី។ លោកមេឃុំព្រៃក្មេង បានសំណូមពរយ៉ាងទទូចដល់អង្គការ-ស្ថាប័នពាក់ព័ន្ធនានាអោយចូលរួមនៅក្នុងការជួយអភិវឌ្ឍន៏ឃុំនេះរួមជាមួយអជ្ញាធរដែនដី ជាពិសេសក្នុងការអប់រំដើម្បីកាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារ, សុខភាព-អនាម័យ និងបច្ចេកទេសកសិកម្ម។

**បញ្ហាចំបងដែលជួបប្រទះនៅក្នុងឃុំ :**

- ខ្វះចំណេះដឹងបច្ចេកទេសផ្នែកធ្វើកសិកម្ម
- ខ្វះស្បៀង (តែងតែជួបប្រទះញឹកញាប់នូវគ្រោះរាំងស្ងួត), ខ្វះប្រភពទឹក
- មានអំពើហឹង្សាក្នុងគ្រួសារញឹកញាប់
- បញ្ហាសុខភាព (ប្រជាពលរដ្ឋភាគច្រើនកើតជំងឺក្រពះ-ពោះវៀន, គ្រុនចាញ់ និងឬសដូងបាត) និងអនាម័យ
- មានការយល់ដឹងតិចតួច និងខ្វះការយកចិត្តទុកដាក់ក្នុងការថែរក្សាធនធានធម្មជាតិ និងបរិស្ថាន

**វត្តមានរបស់អង្គការនានា :** ថ្វីត្បិតតែឃុំព្រៃក្មេង ត្រូវបានចាត់ទុកជាឃុំដែលក្រីក្រក្នុងចំណោមក្រីក្រដទៃទៀតរបស់ស្រុកភ្នំស្រួច ប៉ុន្តែវត្តមាននៃការបំពេញបេសកកម្មផ្នែកការងារអភិវឌ្ឍន៍របស់បណ្តាអង្គការនានានៅមានតិចតួចនៅឡើយ ។ អង្គការដែលកំពុងធ្វើសកម្មភាពនាពេលបច្ចុប្បន្ននៅក្នុងព្រៃក្មេង មាន :

- អង្គការ RHAC : អនុវត្តគំរោងផ្តោតសំខាន់លើផ្នែកសុខភាពបន្តពូជ និងការពន្យារកំណើត
- អង្គការ Prasac និងធនាគារ ACELEDA : អនុវត្តគំរោងឥណទានកម្ចីប្រាក់
- អង្គការ CEDAC : ទើបតែធ្វើការទំនាក់ទំនងដើម្បីអនុវត្តគំរោងក្នុងការជំរុញអោយកសិករធ្វើស្រូវម្លិះតាមគោលការណ៍ធម្មជាតិ ។

**អនុសាសន៍របស់ក្រុមការងារអង្គការ ARD :** យោងតាមលទ្ធផលនៃការអង្កេតជាក់ស្តែង និងជួបពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ មេភូមិ និងប្រជាពលរដ្ឋ យើងឃើញថា*ឃុំព្រៃក្មេង ជាឃុំមួយមានលក្ខណៈសមស្របសំរាប់ធ្វើការជ្រើសរើសជាឃុំគោលដៅដើម្បីអនុវត្តគំរោងអភិវឌ្ឍន៍ចំរុះ* (ជាពិសេសផ្តោតលើការបណ្តុះបណ្តាលប្រជាកសិករអោយមានការយល់ដឹងទាក់ទងនឹងបច្ចេកទេសដាំដុះ និងចិញ្ចឹមសត្វ, ការធ្វើបង្ហាញពីបច្ចេកទេសផលិតកម្មកសិកម្ម, ការអប់រំផ្សព្វផ្សាយអំពីអំពើហឹង្សាក្នុងគ្រួសារ, ការថែរក្សាធនធានធម្មជាតិ-បរិស្ថាន និងសុខភាព-អនាម័យ, គំរោងបង្កើនសន្តិសុខសុវត្ថិភាពស្បៀងតាមរយៈការបង្កើតធនាគារស្រូវ បង្កើតក្រុមសន្សំ ជាដើម, ការអប់រំផ្សព្វផ្សាយអំពីគោលគំនិតអភិវឌ្ឍន៍-ការផ្លាស់ប្តូរទំលាប់មិនសមស្រប ។ល ។) សំដៅឈានទៅរកការកែលំអកំរិតជីវភាពរបស់ប្រជាកសិករ តាមរយៈការអនុវត្តនូវបច្ចេកទេសកសិកម្មសមស្រប និងជោគជ័យ និងការធ្វើអោយស្ថានភាពសុខភាពមានភាពល្អប្រសើរឡើង ។

*ភូមិដៃថ្មី និងភូមិដីក្រហម គឺជាភូមិដែលមានស្ថានភាពក្រីក្រ និងមានបញ្ហាផ្នែកសុខភាពធ្ងន់ធ្ងរជាងគេ ដែលគួរតែត្រូវបានបញ្ចូលជាភូមិគោលដៅគំរូ សំរាប់អនុវត្តសកម្មភាពគំរោងចំរុះ នៅពេលដែលភូមិនានាដទៃទៀតគួរត្រូវបានផ្តោតជាសំខាន់សំរាប់សកម្មភាពផ្សព្វផ្សាយ និងបណ្តុះបណ្តាល ។*

## ៣. ឃុំមហាសាំង :

ឃុំមហាសាំង មានទីតាំងស្ថិតនៅជាប់ជាមួយឃុំតាំងស្យា, ឃុំគីរីវណ្ណ និងមួយផ្នែកជាប់ស្រុកសំរោងទង និងមានភូមិចំនួន ២៦ ស្ថិតនៅក្រោមចំណុះ ។ តាមលោកឡុង សុភ័ត្រា និងលោកអួង ប៊ុនថន សមាជិកក្រុមប្រឹក្សាឃុំមហាសាំង បានអោយដឹងថា ក្នុងចំណោមភូមិទាំង២៦របស់ឃុំ មានភូមិប្រហែលចំនួន៤-៥ ដែលជីវភាពប្រជាពលរដ្ឋរស់នៅមានភាពទន់ខ្សោយ ដែលក្នុងនោះមានភូមិទួលសេរី, បន្ទាប់, ត្រពាំងអោប, ត្រពាំងក្រឡាញ់ និងភូមិទួល ដោយសារតែភូមិទាំងនេះជួបប្រទះនឹងបញ្ហាខ្វះខាតទឹកធ្វើស្រែ, ដីស្រែតិច, ការរំលោភយកដីពីក្រុមទាហាន ។ល ។

**បញ្ហាចំបងដែលជួបប្រទះនៅក្នុងឃុំ :**

- ខ្វះចំណេះដឹងបច្ចេកទេសផ្នែកធ្វើកសិកម្ម
- បញ្ហារំលោភយកដីធ្លីប្រជាពលរដ្ឋពីសំណាក់ក្រុមអ្នកមានអំណាច
- បញ្ហាសុខភាព ( ប្រជាពលរដ្ឋភាគច្រើនកើតជំងឺក្រពះ-ពោះវៀន, គ្រុនឈាម ) និងអនាម័យ
- មានការយល់ដឹងតិចតួចទាក់ទង និងខ្វះការយកចិត្តទុកដាក់ក្នុងការថែរក្សាធនធានធម្មជាតិ និងបរិស្ថាន

**វត្តមានរបស់អង្គការនានា** : អង្គការដែលកំពុងបំពេញបេសកកម្មអភិវឌ្ឍន៍នៅក្នុងមហាសាំង បច្ចុប្បន្ន មាន :

- អង្គការ **ADSA** : អនុវត្តគំរោងផ្តោតសំខាន់លើផ្នែកកសិកម្ម (ដាំដុះ
- អង្គការ **CHE** : អនុវត្តគំរោងផ្នែកកសិកម្ម, សុខភាព (ជីកស្រះ, ធនាគារស្រូវ, បង្គន់អនាម័យ, ដាំដុះ...)
- អង្គការ **CEDAC** : ជំរុញការធ្វើផលិតកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ

**អនុសាសន៍របស់ក្រុមការងារអង្គការ** ARD : យោងតាមលទ្ធផលនៃការអង្កេតជាក់ស្តែង និងជួបពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ មេភូមិ និងប្រជាពលរដ្ឋ យើងឃើញថា*ឃុំមហាសាំង ជាឃុំមួយមានលក្ខណៈសមស្របសំរាប់ធ្វើការជ្រើសរើសជាឃុំគោលដៅដើម្បីអនុវត្តគំរោងអភិវឌ្ឍន៍ចំរុះ* (ជាពិសេសផ្តោតលើការបណ្តុះបណ្តាលប្រជាកសិករអោយមានការយល់ដឹងទាក់ទងនឹងបច្ចេកទេសដាំដុះ និងចិញ្ចឹមសត្វ, ការធ្វើបង្ហាញពីបច្ចេកទេសផលិតកម្មកសិកម្ម, ការថែរក្សាធនធានធម្មជាតិ-បរិស្ថាន និងសុខភាព-អនាម័យ, គំរោងបង្កើនសន្តិសុខសុវត្ថិភាពស្បៀងតាមរយៈការបង្កើតធនាគារស្រូវ បង្កើតក្រុមសន្សំ ជាដើម ។ល ។) សំដៅឈានទៅរកការកែលំអកំរិតជីវភាពរបស់ប្រជាកសិករ តាមរយៈការអនុវត្តនូវបច្ចេកទេសកសិកម្មសមស្រប និងជោគជ័យ និងការធ្វើអោយស្ថានភាពសុខភាពមានភាពល្អប្រសើរឡើង ។

*ភូមិបន្ទាប់ គឺជាភូមិដែលមានស្ថានភាពក្រីក្រ និងមានលក្ខណៈសមស្រប ដែលគួរតែត្រូវបានបញ្ចូលជាភូមិគោលដៅគំរូ សំរាប់អនុវត្តសកម្មភាពគំរោងចំរុះ នៅពេលដែលភូមិនានាដទៃមួយចំនួនទៀតគួរត្រូវបានផ្តោតជាសំខាន់សំរាប់សកម្មភាពផ្សព្វផ្សាយ និងបណ្តុះបណ្តាល ។*

## ៤. ឃុំអូរ :

ឃុំអូរ គឺជាឃុំដែលស្ថិតតាមបណ្តោយផ្លូវជាតិ មានភូមិនៅក្រោមចំណុះចំនួន១៩ និងមានប្រជាពលរដ្ឋសរុបចំនួន ២៦៧៤ គ្រួសារ ។ តាមការអោយដឹងពីលោក អេង ប៊ុនសុង ស្មៀនឃុំអូរ និងប្រជាពលរដ្ឋមួយចំនួនដែលស្ថិតនៅក្នុងភូមិមួយចំនួនដែលក្រុមការងារអង្គការ ARD បានចុះសិក្សាអង្កេតជាក់ស្តែងឃើញថា ថ្វីត្បិតតែឃុំអូរមានភូមិមួយចំនួនហាក់មានស្ថាភាពក្រីក្រ ប៉ុន្តែបើប្រៀបធៀបជាមួយភូមិដែលក្រីក្រនៅក្នុងឃុំជាំសង្កែ ព្រៃក្មេង និងឃុំមហាសាំងខាងលើ ឃើញថាវាមានភាពប្រសើរជាង ហើយម្យ៉ាងទៀតភូមិមួយចំនួនតូចដែលចាត់ទុកថាក្រីក្រនោះ ក៏មានវត្តមានអង្គការអភិវឌ្ឍន៍កំពុងបំពេញបេសកកម្មផងដែរ ជាពិសេសអង្គការទស្សនៈពិភពលោក និងអង្គការ ADSA ដែលគ្របដណ្តប់លើការអភិវឌ្ឍន៍ចំរុះ រួមទាំងផ្នែកកសិកម្ម សុខភាព និងហេដ្ឋរចនាសម្ព័ន្ធ (ស្រះ ផ្លូវ) ផងដែរ ។

**អនុសាសន៍របស់ក្រុមការងារអង្គការ** ARD : យោងតាមលទ្ធផលនៃការអង្កេតជាក់ស្តែង និងជួបពិភាក្សាជាមួយស្មៀនឃុំ និងប្រជាពលរដ្ឋតាមភូមិមួយចំនួន ក្រុមការងារអង្គការ ARD *យល់ឃើញថាឃុំអូរជាឃុំដែលមានស្ថានភាពល្អប្រសើរ និងដែលកំពុងទទួលបានឱកាសក្នុងការអភិវឌ្ឍន៍ពីអង្គការនានាផងដែរនោះ ដូច្នេះឃុំអូរមិនគួរត្រូវបានបញ្ចូលជាឃុំគោលដៅសំរាប់អនុវត្តគំរោងឡើយ ។*

## ៥. ឃុំគីរីវណ្ណ ៖

ឃុំគីរីវណ្ណ គឺជាឃុំមួយដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៤ និងជាទីប្រជុំជនរបស់ស្រុកភ្នំស្រួចផងដែរ ។ តាមរយៈការចុះសិក្សាអង្កេតជាក់ស្តែង និងជួបពិភាក្សាជាមួយប្រជាពលរដ្ឋផ្ទាល់ បានបង្ហាញអោយឃើញថាភូមិទាំងអស់របស់ឃុំគីរីវណ្ណមានស្ថានភាពប្រសើរ និងមានអង្គការអភិវឌ្ឍន៍សំខាន់ៗកំពុងធ្វើសកម្មភាពនៅតាមភូមិមួយចំនួនដែលចាត់ទុកថាជាភូមិក្រីក្ររបស់ឃុំ ក្នុងនោះមានអង្គការទស្សនៈពិភពលោក ដែលធ្វើការងារសំខាន់ផ្តោតលើការសាងសង់អាងស្តុកទឹកសំរាប់ប្រជាពលរដ្ឋ ការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ការសាងសង់អណ្តូងលូ ធុងចំរោះទឹក ការជួយគាំទ្រដល់កុមារកំព្រា និងក្រីក្រ ជាដើម ។ល ។

**អនុសាសន៍របស់ក្រុមការងារអង្គការ ARD** ៖ ដូចគ្នានឹងឃុំអូរដែរ ក្រុមការងារអង្គការ ARD យល់ឃើញថា *ឃុំគីរីវណ្ណ ជាឃុំដែលមានស្ថានភាពល្អប្រសើរ និងដែលកំពុងទទួលបានឱកាសក្នុងការអភិវឌ្ឍន៍ពីអង្គការនានាផងដែរនោះ ដូច្នេះឃុំគីរីវណ្ណ មិនគួរត្រូវបានបញ្ចូលជាឃុំគោលដៅសំរាប់អនុវត្តគំរោងឡើយ ។*

## ៦. ឃុំត្រែងត្រយឹង ៖

ដូចគ្នានឹងឃុំចំនួន២ខាងលើ (ឃុំអូរ និងឃុំគីរីវណ្ណ) ឃុំត្រែងត្រយឹងស្ថិតនៅតាមផ្លូវជាតិ ដែលមានភូមិនៅក្រោមចំណុះ ចំនួន២២ តែឃុំត្រែងត្រយឹង មានភូមិជាច្រើនដែលកំពុងស្ថិតនៅក្នុងស្ថានភាពក្រីក្រ ជាពិសេសភូមិដែលនៅប៉ែកខាងត្បូងផ្លូវជាតិ ដែលស្ថិតនៅឆ្ងាយដាច់ស្រយាល និងស្ថានភាពផ្លូវលំបាក ប៉ុន្តែភូមិទាំងនោះត្រូវបានគាំទ្រការងារអភិវឌ្ឍន៍ដោយអង្គការ LWF ។ មុខរបរជាចំបងរបស់ប្រជាកសិករនៅឃុំត្រែងត្រយឹង គឺការធ្វើស្រែចំការ កាប់អុស និងដុតធ្យូង ដែលតាមរយៈលោកស្រីកែវ សុផាត សមាជិកក្រុមប្រឹក្សាឃុំត្រែងត្រយឹង និងលោក ច្រឹក សុផល ជនបង្គោលឃុំ ទទួលបន្ទុកផ្នែកធនធានធម្មជាតិ និងបរិស្ថាន បានអោយដឹងថា ដីស្រែសំរាប់ប្រជាកសិករបង្កបង្កើនផលស្រូវវស្សា មានចំនួន ៨១៣៨ ហិកតា នៅក្នុងខណៈដែលផ្ទៃដីសំរាបចំការឈើហូបផ្លែមានរហូតដល់ទៅ ១២២៧៣ ហិកតា និងចំការដំណាំរួមផ្សំ (សណ្តែកដី, ឪឡឹក...) មាន៤៧៩៧ ហិកតា ។

តាមការចុះសិក្សាអង្កេតភូមិមួយចំនួនដែលនៅសេសសល់ពីការចូលអភិវឌ្ឍន៍របស់អង្គការ LWF ហើយដែលបណ្តាភូមិទាំងនោះស្ថិតនៅជិតផ្លូវជាតិ បានបង្ហាញថា កសិករភាគច្រើនរស់នៅធ្វើចំការជាពិសេសចំការឈើហូបផ្លែ ទោះបីពិនិត្យមើលឃើញស្ថានភាពលំនៅឋានរបស់គាត់ខ្លះមានទំហំតូច តែស្ថានភាពរស់នៅហាក់មានភាពប្រសើរជាងភូមិនានានៅឃុំខាងលើដែលស្ថិតនៅឆ្ងាយពីផ្លូវជាតិ ។

**អនុសាសន៍របស់ក្រុមការងារអង្គការ ARD** ៖ ដូចគ្នានឹងឃុំអូរ និងឃុំគីរីវណ្ណដែរ ក្រុមការងារអង្គការ ARD យល់ឃើញថា *ឃុំត្រែងត្រយឹង ជាឃុំដែលមានស្ថានភាពល្អប្រសើរ និងដែលកំពុងទទួលបានឱកាសក្នុងការអភិវឌ្ឍន៍ពីអង្គការនានាផងដែរនោះ ដូច្នេះឃុំត្រែងត្រយឹង មិនគួរត្រូវបានបញ្ចូលជាឃុំគោលដៅសំរាប់អនុវត្តគំរោងឡើយ ។*

## VII. អនុសាសន៍រួម

ឆ្លងតាមការចុះសិក្សាអង្កេត ក្រុមការងារអង្គការ **ARD** *បានកំណត់នូវឃុំចំនួន៣ ដែលអាចមានលទ្ធភាពត្រូវបានជ្រើសរើសជាឃុំគោលដៅសំរាប់អនុវត្តគំរោង គឺឃុំជាំសង្កែ, ឃុំព្រៃក្មេង និងឃុំមហាសាំង ដែលឃុំទាំងនេះមានភូមិជាច្រើនស្ថិតនៅឆ្ងាយពីផ្លូវជាតិ ហើយដែលជីវភាពប្រជាពលរដ្ឋនៅមានកំរិតទាប ។*

ចំពោះការជ្រើសរើសភូមិគោលដៅវិញ ក្រុមការងារអង្គការ **ARD** សូមលើកជាអនុសាសន៍ថា *គួរត្រូវបានបែងចែងជាពីរប្រភេទផ្សេងគ្នា គឺភូមិគោលដៅគំរូសំរាប់អនុវត្តសកម្មភាពអភិវឌ្ឍន៍ចំរុះ និងភូមិគោលដៅសំរាប់ការងារអប់រំផ្សព្វផ្សាយ ។* ការបែងចែងជាពីរប្រភេទផ្សេងគ្នានេះ គឺផ្អែកទៅលើលក្ខណ្ឌដូចខាងក្រោម :

១. **ភូមិគោលដៅគំរូសំរាប់អនុវត្តសកម្មភាពអភិវឌ្ឍន៍ចំរុះ** *គឺជាបណ្តាភូមិដែលមានប្រជាពលរដ្ឋមានស្ថានភាពជីវភាពក្រីក្រ ដែលគ្មាន រឺមានតិចតួចបំផុតនូវវត្តមានអង្គការចូលអភិវឌ្ឍន៍ ។* ភូមិទាំងនេះ គួរត្រូវបានគាំទ្រនូវសកម្មភាពចំរុះ ដែលក្នុងនោះមានទាំងការបណ្តុះបណ្តាល, ការធ្វើបង្ហាញ, និងការបង្កើតជាក្រុមកសិករ និងធនាគារស្រូវ-សត្វ សំដៅអាចកែលំអកំរិតជីវភាពប្រកបដោយប្រសិទ្ធិភាព។ *ក្រុមការងារអង្គការ ARD ចាប់អារម្មណ៍ និងលើកជាអនុសាសន៍សំរាប់ភូមិចំនួន ៥ ដើម្បីជ្រើសរើសជាភូមិគោលដៅគំរូ សំរាប់អនុវត្តសកម្មភាពអភិវឌ្ឍន៍ចំរុះ គឺ ២ភូមិក្នុងឃុំជាំសង្កែ (ភូមិសាលា និង ភូមិតានៃ), ២ភូមិក្នុងឃុំព្រៃក្មេង (ភូមិដៃថ្មី និងភូមិដីក្រហម) និង១ភូមិក្នុងឃុំមហាសាំង (ភូមិបន្ទាប់) ។*

២. **ភូមិគោលដៅសំរាប់ការងារអប់រំផ្សព្វផ្សាយ :** *គឺជាបណ្តាភូមិដែលមានប្រជាពលរដ្ឋមានស្ថានភាពក្រីក្រ តែមានអង្គការអភិវឌ្ឍន៍កំពុងបំពេញបេសកកម្ម ។* ការជ្រើសរើសភូមិទាំងនេះជាភូមិគោលដៅ គឺសំរាប់បំពេញបន្ថែមនូវផ្នែកខ្លះដែលអង្គការនានាមិនបានធ្វើសកម្មភាព ជាពិសេសទាក់ទងនឹងការបណ្តុះបណ្តាល អប់រំផ្សព្វផ្សាយពាក់ព័ន្ធនឹងបច្ចេកទេសកសិកម្ម អំពើហឹង្សាក្នុងគ្រួសារ អប់រំសុខភាព-អនាម័យ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន។ *ក្រុមការងារអង្គការ ARD ចាប់អារម្មណ៍ និងលើកជាអនុសាសន៍សំរាប់ភូមិចំនួន ១៥ ដើម្បីជ្រើសរើសជាភូមិគោលដៅសំរាប់ការងារអប់រំផ្សព្វផ្សាយ គឺ ៥ ភូមិក្នុងឃុំជាំសង្កែ (ភូមិព្រៃឫស្សី, ក្បាលទឹកលើ, ក្បាលទឹកក្រោម, ដូង និងភូមិថ្មី), ៦ភូមិក្នុងឃុំព្រៃក្មេង (ភូមិព្រៃ, ក្រៀលបួស, ស្រែត្រពាំង, ព្រៃឈើទាល, ព្រៃក្បុង និងភូមិកណ្តាល) និង ៤ភូមិក្នុងឃុំមហាសាំង (ភូមិត្រពាំងអោប, ទួលសេរី, ច្រកត្រាច និងភូមិត្រពាំងក្រឡាញ់) ។*

----------------------------------------